CCCN

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីការប្រសើរឡើង
Working Together for Positive Change

# សេចក្តីថ្លែងការណ៍នៃសង្គមស៊ីវិលកម្ពុជា សម្រាប់សន្និសីទនៃភាគីជាសមាជិកអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុលើកទី ២០ (COP២០) និងសម័យប្រជុំលើកទី ១០ នៃកិច្ចប្រជុំភាគី (CMP១០) នៅក្រុងលីម៉ា ប្រទេសប៉េរូ

## សេចក្តីផ្តើម

របាយការណ៍វាយតម្លៃលើកទី៥របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) បញ្ជាក់ថា ការឡើងកម្តៅពិភពលោកគឺមានលក្ខណៈជាក់ប្រាកដមិនអាចប្រកែកបាន។ ការប្រែប្រួលអាកាសធាតុបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានដល់សុខភាព សុវត្ថិភាព និងជីវភាពរបស់ប្រជាជន ជាពិសេសប្រជាជនក្រីក្រនៅក្នុងប្រទេសក្រីក្របំផុតដែលត្រូវបានរំពឹងថា នឹងរងការលំបាកមុនគេ និងច្រើនជាងគេបំផុត និងរួមទាំងជីវចំរុះដ៏ទៃទៀត។ ប្រសិនបើការព្យាករណ៍ និងការឆ្លើយតបលើការប្រែប្រួលអាកាសធាតុមិនមានប្រសិទ្ធភាពនោះទេ ឧបសគ្គជាច្រើននឹងកើនឡើងដែលរារាំងដល់ការកាត់បន្ថយភាពក្រីក្រនាពេលអនាគត និងធ្វើឲ្យសមិទ្ធផលសង្គម សេដ្ឋកិច្ចសំខាន់ៗនានាដែលសម្រេចបានដោយប្រទេសកំពុងអភិវឌ្ឍត្រូវដើរត្រឡប់ក្រោយ។

លើសពីនេះទៅទៀត ការប្រែប្រួលអាកាសធាតុនឹងក្លាយជាបញ្ហាប្រឈមមួយដែលអាចរារាំងយ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងកិច្ចប្រឹងប្រែងក្នុងការលុបបំបាត់ភាពក្រីក្រក្នុងតំបន់។ ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសដែលមានភាពងាយរងគ្រោះខ្លាំងបំផុតទៅនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់អាស៊ីអគ្នេយ៍ ដោយសារសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅមានកម្រិត។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាទទួលរងផលប៉ះពាល់កាន់តែញឹកញាប់ឡើង ដោយសារគ្រោះធម្មជាតិដូចជាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតធ្វើឲ្យមានការបាត់បង់ជីវិត និងការខូចខាតផ្នែកសេដ្ឋកិច្ចជាច្រើន។[១]

យោងទៅតាមការសិក្សាស្តីពីការវាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំរបស់ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញថា នៅក្នុងឆ្នាំ២១០០ របបទឹកភ្លៀងនឹងកើនឡើងពី ៣% ដល់ ៣៥% ដែលធ្វើឲ្យទឹកជំនន់កើនឡើងយ៉ាងឆាប់រហ័ស ស្របពេលដែលសីតុណ្ហភាពនឹងកើនឡើងពី ១.៣អង្សា ដល់ ២.៥អង្សា។ ប្រទេសកម្ពុជាជាប្រទេសមួយដែលមានភាពងាយរងគ្រោះបំផុតជាពិសេសដោយសារគ្រោះមហន្តរាយដែលទាក់ទងទៅនឹងអាកាសធាតុ ខណៈពេលដែលប្រជាជនកម្ពុជាជាង ៨០ភាគរយជាកសិករ។

របាយការណ៍វាយតម្លៃលើតម្រូវការក្រោយទឹកជំនន់ឆ្នាំ២០១៣ ដែលរៀបចំឡើងដោយ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) នៅក្នុងខែមេសា ឆ្នាំ២០១៤ បានបង្ហាញថា ព្យុះសង្ឃរា និងគ្រោះទឹកជំនន់ក្នុងឆ្នាំ ២០០៩, ២០១១ និង ២០១៣ បានធ្វើឲ្យខូចខាត និងបាត់បង់ផ្ទះសំបែង ដំណាំស្រូវ និងហេដ្ឋារចនាសម្ព័ន្ធសរុបប្រមាណជាង ១០០ លានដុល្លារអាមេរិក។ គ្រោះទឹកជំនន់ក្នុងឆ្នាំ២០១៣ បានសម្លាប់មនុស្ស ១៦៨

[១] កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA), UNDP ឆ្នាំ ២០០៦។

នាក់ដែលភាគច្រើនជាកុមារ ប៉ះពាល់ដល់ ៣៧៧ ៣៥៩ គ្រួសារ និងប៉ះពាល់ដល់មនុស្សរាយប្រមាណ ១.៨ លាននាក់។

ក្រៅពីគ្រោះទឹកជំនន់ ប្រទេសកម្ពុជាក៏ធ្លាប់មានបទពិសោធន៍រងគ្រោះរាំងស្ងួតច្រើន ខណៈសីតុណ្ហភាពកើនឡើងទៅ ០.៨អង្សា ជាពិសេសក្នុងរដូវប្រាំង។ សីតុណ្ហភាពពេលយប់ និងពេលថ្ងៃបានកើនឡើងទាំងក្នុងរដូវវស្សា និងរដូវប្រាំង។[២] សីតុណ្ហភាពប្រចាំឆ្នាំនឹងកើនឡើងយ៉ាងលឿនក្រោយឆ្នាំ២០៣០។[៣]

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកម្ពុជាបច្ចុប្បន្នកម្មឆ្នាំ២០១៤-២០១៨ (NSDP-II) ផែនការយុទ្ធសាស្ត្រជាតិប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP ២០១៤-២០២៣) និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុជាបញ្ហាមួយនៃបញ្ហាប្រឈមផ្នែកអភិវឌ្ឍន៍សំខាន់ៗ និងរួមទាំងសកម្មភាពជាក់ស្តែងនានាដើម្បីលើកឡើងពីការប្រែប្រួលអាកាសធាតុទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**ក្នុងនាមយើងខ្ញុំជាអង្គការសង្គមស៊ីវិលកម្ពុជា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និង បណ្តាញស្តីពីការប្រែប្រួលអាកាសធាតុ នៅកម្ពុជា សូមធ្វើការទាមទារដូចខាងក្រោម៖**

## ការកាត់បន្ថយហេតុនៃការប្រែប្រួលអាកាសធាតុ

- តម្រូវការជាបន្ទាន់ និងចាំបាច់ដើម្បីបង្កើនមហិច្ឆតា និងកំណត់គោលដៅច្បាស់លាស់ក្នុងការកាត់បន្ថយការបំភាយដើម្បីរក្សាកម្រិតសីតុណ្ហភាពឲ្យ**នៅក្រោម ២អង្សា ដល់ឆ្នាំ២១០០**។
- ដើម្បីសម្រេចគោលដៅនេះ ភាគីនៃឧបសម្ព័ន្ធ ១ ត្រូវ**ធ្វើសកម្មភាពជាបន្ទាន់**ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។ ការប្តេជ្ញាត្រូវចាប់ផ្តើមពីប្រទេសនីមួយៗ ហើយពង្រីកដល់កម្រិតតំបន់ និងសកលលោក។ កិច្ចខិតខំប្រឹងប្រែងក្នុងការចូលរួមកាត់បន្ថយការបំភាយបន្ថែមទៀត របស់ភាគីពាក់ព័ន្ធនៃ UNFCCC ក៏មានសារៈសំខាន់ដើម្បីចូលរួមថែរក្សាបរិស្ថានផងដែរ។
- **គួរតែរក្សា ត្រួតពិនិត្យ និងតាមដានរាល់ទិន្នន័យរាយលម្អិត**ស្តីពីការកាត់បន្ថយការបំភាយសកល និងការប្តេជ្ញាចិត្តដែលនៅក្រោមពិធីការក្យូតូលើកទីពីរ និងកិច្ចខិតខំប្រឹងប្រែងដោយស្ម័គ្រចិត្តនានាដូចបញ្ជាក់ និងតាមដានដោយ UNFCCC ។
- UNFCCC គួរតែបង្កើតអនុលោមភាពស្តីពី**ទីផ្សារវេជបូក**។ លើសពីនេះទៅទៀត UNFCCC គួរតែបង្កើត**មូលនិធិវេជបូក** សម្រាប់ប្រទេសកំពុងអភិវឌ្ឍដើម្បីទទួលបានប្រកបដោយតម្លាភាព និងគណនេយ្យភាព

---

[២] របាយការសិក្សា (២០០៨) Mc Sweeny, New & Lizcano, សាកលវិទ្យាល័យ Oxford, ការវិភាគនៃការអង្កេតសីតុណ្ហភាព ពីឆ្នាំ១៩៦០ ដល់ ២០០៦។

[៣] ក្រសួងបរិស្ថាន (២០១២) របាយការណ៍ជាតិលើកទី២

- **ប្រព័ន្ធព័ត៌មានសុវត្ថិភាពស្តីពីរេដបូក** (SIS) គួរតែបញ្ចូលព័ត៌មានដែលទាក់ទងទៅនឹងសិទ្ធិកាន់កាប់ សិទ្ធិជនជាតិដើមភាគតិច សហគមន៍ដែលអាស្រ័យដោយព្រៃឈើ កត្តានៃការបាត់បង់ព្រៃឈើ ជីវចម្រុះ អត្រានៃការកាត់បន្ថយការបាត់បង់ព្រៃឈើ និងការបំលែងព្រៃធម្មជាតិ។

## ការបាត់បង់ និងការខូចខាត

យោងតាមយន្តការទីក្រុងវើសអន្តរជាតិស្តីពីការខូចខាត និងការបាត់បង់ យើងខ្ញុំចង់ឃើញពីដំណើរការអនុវត្ត ដូចខាងក្រោម៖

- **យន្តការដោះស្រាយការខូចខាត និងការបាត់បង់**ត្រូវឆ្លុះបញ្ចាំង និងបញ្ជាក់ឲ្យបានច្បាស់លាស់ក្នុងកិច្ចព្រមព្រៀងអាកាសធាតុពិភពលោកនៅក្នុងសន្និសីទនៃភាគីលើកទី២១(COP២១)ក្នុងទីក្រុងប៉ារីស ប្រទេសបារាំង
- **ត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការណែនាំច្បាស់លាស់**ដើម្បីលើកឡើងពីយន្តការដោះស្រាយការខូចខាត និងការបាត់បង់ដែលពាក់ព័ន្ធទៅនឹងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ។
- **ការជួយសម្រួលក្នុងការកៀរគរ និងការជំរុញលើការជួយគាំទ្រ**ផ្នែកហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការកសាងសមត្ថភាពពិតជាមានសារៈសំខាន់ក្នុងការពង្រឹងរចនាសម្ព័ន្ធ និងវិធានការដែលមានស្រាប់ការអនុវត្តក្របខណ្ឌស្តីពីការដោះស្រាយការខូចខាត និងការបាត់បង់។
- គួរតែ**បន្ថែមមូលនិធិ**សម្រាប់ការដោះស្រាយការខូចខាត និងការបាត់បង់ ទៅក្នុងមូលនិធិអាកាសធាតុបៃតង។

## ការបន្សាំ

- ត្រូវធានាឲ្យមាន**ការចូលរួមឲ្យបានពេញលេញ** ពីសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ពន្ធ័សំខាន់ៗដ៏ទៃទៀតនៅគ្រប់កម្រិតទាំងអស់ក្នុងការបង្កើត ការអនុវត្ត និងការតាមដានដំណើរការផែនការជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAP)។
- **ត្រូវធានានិងផ្អែកលើតំរូវការប្រទេស និងសហគមន៍មូលដ្ឋាន** ក្នុងដំណើរការ និងវិធានការក្នុងការបង្កើត និងការអនុវត្ត ហើយតាមដានយុទ្ធសាស្រ្តបន្សាំនានា។
- **ប្រព័ន្ធអេកូឡូស៊ីកសិកម្ម(Ago-ecology)** គួរដាក់បញ្ចូលនៅក្នុងយុទ្ធសាស្រ្តបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលជាប្រយោជន៍យ៉ាងច្រើនសំរាប់កសិកម្មខ្នាតតូច ក្នុងការពង្រឹងសន្តិសុខស្បៀង និងភាពធន់ទៅនឹងអាកាសធាតុ។ ម្យ៉ាងវិញទៀត គួរតែបញ្ជ្រាបនិងឆ្លុះបញ្ចាំងពី**ការបញ្ជ្រាបយេនឌ័រ** ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។
- **កម្មសិទ្ធិបញ្ញា** (IPR) មិនគួរជាឧបសគ្គក្នុងការផ្ទេរបច្ចេកវិទ្យាទេ។

## ហិរញ្ញវត្ថុអាកាសធាតុ

ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសក្រីក្រ និងងាយរងគ្រោះបំផុតក្នុងពិភពលោកដោយសារការប្រែប្រួលអាកាសធាតុ **ត្រូវការធនធានហិរញ្ញវត្ថុច្រើន**ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់អវិជ្ជមាននានា។ ប្រជាកសិកររបស់យើងបានខាតបង់ប្រាក់យ៉ាងច្រើនដោយសារផលប៉ះពាល់អវិជ្ជមានទាំងនេះ។ ក្នុងហេតុផលនេះ យើងខ្ញុំសូមទាមទារដូចខាងក្រោម៖

- យើងខ្ញុំទទួលស្គាល់ និងសាទរចំពោះបណ្តាប្រទេសដែលបានសន្យាចូលរួមក្នុង**មូលនិធិអាកាសធាតុបៃតង** ដែលមានទឹកប្រាក់ចំនួន **៩.៣ ពាន់លានដុល្លារអាមេរិក**។ យើងក៏សង្ឃឹមថា ក្នុងឆ្នាំ២០២០ យើងនឹងបានដឹងពីទឹកប្រាក់ចំនួន **១០០ ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ**ដែលបានសន្យាក្នុងសន្និសីទនៃភាគីលើកទី១៥ (COP១៥) ដើម្បីធានាមានហិរញ្ញប្បទានគ្រប់គ្រាន់សម្រាប់ការធ្វើប្រត្តិបត្តិការមូលនិធិអាកាសធាតុបៃតង។ មូលនិធិគួរតែជាការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុរយៈពេលវែង។ ប្រសិនបើមិនមានមូលនិធិទាំងនេះទេ នោះវានឹងមិនមានភាពពិតប្រាកដនៃកិច្ចព្រមព្រៀងអាកាសធាតុពិភពលោកក្នុងសន្និសីទនៃភាគីលើកទី២១ (COP២១) ទេ។
- ការគាំទ្រផ្នែកហិរញ្ញវត្ថុអាកាសធាតុចំពោះប្រទេសអភិវឌ្ឍតិចតួចបំផុត (LDCs) ដូចជាប្រទេសកម្ពុជា គប្បីមានទម្រង់ជា**ហិរញ្ញប្បទានឥតសំណង មិនមែនជាប្រាក់កម្ចី** និងជា**មូលនិធិថ្មី និងបន្ថែម** លើជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)។
- ការគាំទ្រផ្នែកហិរញ្ញវត្ថុអាកាសធាតុតាមរយៈយន្តការ**មូលនិធិអាកាសធាតុបៃតង** និងយន្តការដ៏ទៃទៀតដែលមានស្រាប់ប្រកបដោយតម្លាភាពដូចជា**មូលនិធិវិនិយោគអាកាសធាតុ** (CIF) ។
- មូលនិធិអាកាសធាតុគួរតែគាំទ្រ**តម្រូវការ និងអាទិភាពនៃប្រទេសនីមួយៗ ជាពិសេសស្របទៅតាមយន្តការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ**។
- សង្គមស៊ីវិលគួរតែ**ចូលរួមឲ្យបានពេញលេញ**ក្នុងការគ្រប់គ្រងហិញ្ញវត្ថុអាកាសធាតុនៅគ្រប់កម្រិតទាំងអស់ ដើម្បីធានាឲ្យមានការអនុវត្តអភិបាលកិច្ចល្អ ហើយការគាំទ្រនោះនឹងទៅដល់ប្រទេសដែលងាយរងគ្រោះបំផុត។

គាំទ្ររួមគ្នាដោយ៖

### សូមទំនាក់ទំនង


១. **លោកបណ្ឌិត តឹក វណ្ណារ៉ា**
តួនាទី៖ នាយកប្រត្តិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា/សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលស្តីពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២១៤ ៤២៩/(+៨៥៥) ១២ ៧៩៣ ៤៨៩
អ៊ីម៉ែល៖ vannara@ngoforum.org.kh

២. **លោក ទេព ប៊ុននី**
តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល នៃបណ្តាញស្តីពីការប្រែប្រួលអាកាសធាតុ នៅកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥)១២ ៩០០ ៦០៤/(+៨៥៥)១៥ ៩១០ ០០០
អ៊ីម៉ែល៖ secretariat@cccn.org.kh

៣. **លោក ណុប ប៉ូលីន**
តួនាទី៖ បុគ្គលិកអង្គការ DCA/CA
ទូរស័ព្ទ៖(+៨៥៥)២៣ ២១៦ ២៦១/(+៨៥៥)៩២ ២២២៨១១
អ៊ីម៉ែល៖ nopo@dca.dk